

# មេម៉ាយច្រើនយ៉ាង

ចាស់ថាបាយកកក៏បាយ   ស៊ូយកមេម៉ាយសប្បាយចិត្តណាស់ខ្ញុំ   ខ្លាចប៉ះក្មេងក្វាយក្រមុំ
វរវើកហើយខ្ញុំ   បើក្រមុំច្រើនភ្លើង។

កូនអើយកាលម៉ែមេម៉ាយ   ពុកកូនគាត់ស្លាយក្រមុំភូមិយើង   តាយាយឥតបីកាន់ជើង
ចុះឡើងៗមកយកម៉ែមេម៉ាយ។
ការហើយរកស៊ីធូរណាស់   មានលុយសង់ផ្ទះមានប្រាក់កាសចាយ   ពុកកូនគាត់ថាកកក៏បាយ
យកប្រពន្ធមេម៉ាយ   មានចាយសមរម្យ។

ម៉ែអើយបើមេម៉ាយស្តុក   មានស្រែដើងស្រុកសំបុកដើងភូមិ   ខ្លាចគេមិនព្រមស្នេហ៍រូបខ្ញុំ
គេចាំលោកធំសុំធ្វើប្រពន្ធចុង។

មេម៉ាយច្រើនយ៉ាងណាស់កូន   ខ្លះតែងតែខ្លួនមិនចេះស្មៀកសារុង   ដេករកតែពូកអេប៉ុង
ខ្លះមានតែកុងបើកឡានឱ្យជិះ។
ខ្លះទៀតមេម៉ាយប្តីលែង   ផឹកស្រាលេងល្បែងឫកពារសំគិះ   កុំបៀតមេម៉ាយបែបនេះ
កូនប្រុសត្រូវរិះរកមេម៉ាយគ្រប់លក្ខណ៍។

ដូចម្តេចមេម៉ាយក្តៅស្រួយ   លែងមួយយកមួយចេះលេបចេះខ្ជាក់
ម៉េចទៅមេម៉ាយគ្រប់លក្ខណ៍   ចេះទុកចេះដាក់ចេះថ្នាក់ថ្នមប្តី។
ដូចម៉ែហើយនិងពុកឯង   ល្អុកល្អឺនក្រៃលែងតែងមានសិរី
ខ្លាចមិនទាន់សម័យថ្មី   កូនប្រុសកុំភ័យស៊ីសងយើងមានប្រាក់។

ចង់បានគេចេះរកទុក   មានបានថ្ងៃមុខស្ត្រីចេះទុកដាក់
ម៉ែឃើញហើយមេម៉ាយគ្រប់លក្ខណ៍   បើកហាងដេរប៉ាក់  មានប្រាក់ចងការ។

**សិល្បករៈ រិន សាវ៉េត និង ពេជ្រ សោភា**

Khmer Story Lovers